# សហគមន៍ខ្មែរកម្ពុជាក្រោម

THE KHMER KAMPUCHEA KROM COMMUNITY
LA COMMUNAUTÉ DU KHMER KAMPUCHEA KROM

លេខ: ......... ស.ខ.ក.ក.

# សេចក្តីអំពាវនាវ

ថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៤ខាងមុខនេះ អង្គការ-សមាគមខ្មែរកម្ពុជាក្រោម នឹងរៀបចំវេទិកាសាធារណៈមួយនៅទីស្នាក់ការសមាគមខ្មែរកម្ពុជាក្រោម ដើម្បីសិទ្ធិមនុស្ស និង អភិវឌ្ឍន៍ ស្ថិតនៅភូមិគោកឃ្លាំង សង្កាត់ភ្នំពេញថ្មី ខណ្ឌសែនសុខ រាជធានីភ្នំពេញ ក្រោមប្រធានបទ ទឹកដីខ្មែរកម្ពុជាក្រោម។

វេទិកានេះមានគោលបំណងប្រមូលយកអនុសាសន៍នានា ឬ ឯកសារផ្សេងៗ ដែលទាក់ទងនឹងទឹកដីខ្មែរកម្ពុជាក្រោមពីព្រះសង្ឃ និងប្រជារាស្ត្រខ្មែរថែមទៀត ដើម្បីចងក្រងជាឯកសារផ្លូវការជូនរដ្ឋាភិបាលសាធារណរដ្ឋសង្គមនិយមវៀតណាម ឲ្យទទួលស្គាល់ការពិតនៃប្រវត្តិសាស្ត្រទឹកដីខ្មែរកម្ពុជាក្រោម។ ពីព្រោះលោក ត្រឹង វ៉ាន់ថុង អ្នកនាំពាក្យស្ថានទូតវៀតណាមប្រចាំព្រះរាជាណាចក្រកម្ពុជា បានថ្លែងបំភ្លៃការពិតនៃប្រវត្តិសាស្ត្រខ្មែរថា ទឹកដីខ្មែរកម្ពុជាក្រោម ជាទឹកដីរបស់វៀតណាមតាំងពីយូរយារណាស់មកហើយ បារាំងមិនបានកាត់ឲ្យវៀតណាមទេ។ ក្នុងនាមអ្នកនាំពាក្យស្ថានទូត ដែលជាតំណាងឲ្យរដ្ឋាភិបាលសាធារណរដ្ឋសង្គមនិយមវៀតណាម លោក ត្រឹង វ៉ាន់ថុង ត្រូវតែទទួលខុសត្រូវចំពោះការថ្លែងរបស់ខ្លួន ហើយបើលោក ត្រឹង វ៉ាន់ថុង មិនបង្ហាញឯកសារដែលបញ្ជាក់ថា ទឹកដីកម្ពុជាក្រោមជាទឹកដីរបស់វៀតណាមជាយូរយារមកហើយទេនោះ ត្រូវតែសុំទោសប្រជាពលរដ្ឋខ្មែរជាសាធារណៈ ព្រោះជាការប្រមាថមើលងាយប្រជារាស្ត្រខ្មែរខ្លាំងណាស់។

សេចក្តីដូចបានប្រគេន និងជម្រាបជូនខាងលើ ខ្ញុំព្រះករុណាខ្ញុំ សូមអំពាវនាវព្រះតេជព្រះគុណម្ចាស់គ្រប់ព្រះអង្គ បងប្អូនរួមឈាមទាំងអស់ ព្រះមេត្តា និងមេត្តា ជួយឧបត្ថម្ភជាថវិកា ឬជាទឹកបរិសុទ្ធតាមសទ្ធាជ្រះថ្លា ដើម្បីខ្ញុំព្រះករុណាខ្ញុំមានលទ្ធភាពរៀបចំវេទិកាដោយជោគជ័យ។

អង្គការ-សមាគមខ្មែរកម្ពុជាក្រោម សង្ឃឹមយ៉ាងមុតមាំទៅលើស្មារតីនៃឧត្តមគតិស្នេហាជាតិរបស់ព្រះករុណាគ្រប់ព្រះអង្គ និងបងប្អូនរួមឈាម ក្នុងការជួយឧបត្ថម្ភរៀបចំវេទិកានេះទាំងស្រុង។

សូមព្រះករុណាគ្រប់ព្រះអង្គ និងបងប្អូនរួមឈាមទទួលនូវការគោរពរាប់អានដ៏ខ្ពង់ខ្ពស់ អំពីខ្ញុំព្រះករុណាខ្ញុំ។

រាជធានីភ្នំពេញ, ថ្ងៃទី២៣ ខែមិថុនា ឆ្នាំ២០១៤
ប្រធានសហគមន៍ខ្មែរកម្ពុជាក្រោម

**ថាច់ សេដ្ឋា**
អតីតសមាជិកព្រឹទ្ធសភា

ព័ត៌មានបន្ថែម សូម ទាក់ទងមកលេខទូរស័ព្ទ:
០៩៣ ៤៧ ៤៧ ០៦, ០១២ ៩៣៣ ៦៩៩
០១១ ៧២៤ ៥៨៣, ០១២ ៨៨០ ៣៨៨